# សុន្ទរកថា
# របស់ឯកឧត្តម អ៊ុក ប្រថា រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម
# ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដើម្បីក្លាយជា ភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាក
# ក្នុង ព្រះរាជាណាចក្រកម្ពុជា
# ភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤

**ឯកឧត្តម លោកជំទាវ**

**អស់លោក លោកស្រី អ្នកនាងកញ្ញា**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ និងកិត្តិយស ដែលបានចូលរួមបើកកម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីក្លាយជា ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមឆ្លៀតយកឱកាសនេះផងដែរ ដើម្បីសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះនាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលបានរៀបចំវគ្គបណ្តុះបណ្តាលនេះឡើង និងអរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលមានវត្តមាននៅទីនេះ។

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** ជាប្រមុខ បានអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ១ និងទី ២ ប្រកបដោយជោគជ័យក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះដោយសម្រេចបាននូវសន្តិភាពយូរអង្វែង លើកតម្កើងជីវភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍ប្រកបដោយចេរភាព ដែលធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនលើគ្រប់វិស័យ តាមរយៈកំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា។ ទន្ទឹមនឹងនេះផងដែរ រាជរដ្ឋាភិបាលបានធ្វើទំនើបភាវូបនីយកម្មគោលនយោបាយនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច ទៅក្នុង តំបន់ និងពិភពលោក។

វិស័យកម្មសិទ្ធិបញ្ញា បានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ប្រទេសកម្ពុជាក្នុងអំឡុងពេលនៃការធ្វើសមាហរណកម្មនៅក្នុងតំបន់ ជាពិសេសការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ក្រោមការជួយឧបត្ថមពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក កម្ពុជាបានបង្កើតច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមាន

អត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងថ្មីៗនេះបានអនុម័តច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ។

ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា បានដាក់ចេញនូវផែនការអភិវឌ្ឍន៍វិស័យកម្មសិទ្ធិបញ្ញា ដែលមាន ៥២ សកម្មភាព សម្រាប់អនុវត្តពីឆ្នាំ ២០១២ ដល់ ២០១៤ ដើម្បីលើកតម្កើងវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជា ដែលមកទល់ពេលនេះបានបញ្ចប់ការអនុវត្តសកម្មភាព ចំនួន ១៧ ចំណែកសកម្មភាពចំនួន២១ ទៀតបានបញ្ចប់ផ្នែកខ្លះ និងកំពុងបន្តអនុវត្ត។

ទន្ទឹមនឹងនេះផងដែរ ដើម្បីត្រៀមអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្រោមការជួយឧបត្ថម្ភពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក បានរៀបចំសេចក្តីព្រាងយុទ្ធសាស្រ្តកម្មសិទ្ធិបញ្ញាជាតិរបស់កម្ពុជាដែលដាក់ចេញនូវគំនិតផ្តួចផ្តើម ដែលគ្របដណ្តប់លើវិស័យ កសិកម្ម វប្បធម៌ ការអប់រំ ទេសចរណ៍ សុខាភិបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម ដើម្បីសម្រេចបាននូវគោលបំណងសេដ្ឋកិច្ច វប្បធម៌ សមត្ថភាព និងបទដ្ឋានច្បាប់។

ដើម្បីចូលរួមចំណែកក្នុងការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាលអាណត្តិថ្មី និងជម្រុញការងារកម្មសិទ្ធិបញ្ញាឲ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីសម្រួលដល់ធុរៈជន ក៏ដូចជាភ្នាក់ងារតំណាងស្របច្បាប់ក្រសួងពាណិជ្ជកម្ម បានដាក់ឲ្យសាធារណជន អាចធ្វើការស្រាវជ្រាវម៉ាក ដែលបានចុះបញ្ជីរួច តាមប្រព័ន្ធអ៊ីនធឺណែត (Internet) និង ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអ៊ីនធឺណែត (E-Filing)។ នៅពេលខាងមុខ គេហទំព័រនាយកដ្ឋានកម្មសិទ្ធិបញ្ញា ឬលេខាធិការដ្ឋានកម្មសិទ្ធិបញ្ញា នឹងធ្វើការភ្ជាប់ជាមួយអាស៊ាន (ASEAN) និងសហគមន៍អឺរ៉ុប (EU) ដែលនៅពេលនោះយើងអាចស្រាវជ្រាវម៉ាក (Mark Search) ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្មរបស់បណ្តាលប្រទេសអាស៊ាន និងសហគមន៍អឺរ៉ុបបាន។

នៅក្នុងបរិបទសាកលភាវូបនីយកម្ម ការកសាងហេដ្ឋារចនាសម្ព័ន្ធច្បាប់ដ៏រឹងមាំ ការកសាងសមត្ថភាព គឺជាចំណុចគន្លឹះមួយ ក្នុងចំណោមចំណុចគន្លឹះដទៃទៀត សម្រាប់ធ្វើការប្រកួតប្រជែង និងទាញយកផលប្រយោជន៍ឲ្យបានកាន់តែច្រើនថែមទៀតពីពាណិជ្ជកម្មអន្តរជាតិ ។

ស្របតាមមាត្រា ៥៨ និង ៥៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងប្រកាសលេខ ០៤៥ ព.ណ ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្រសួងពាណិជ្ជកម្ម រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីក្លាយជា ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងគ្រប់គ្រង និងពង្រឹងសមត្ថភាពរបស់តំណាងស្របច្បាប់ នៃម្ចាស់ម៉ាក ដើម្បីសម្រួលដល់ការងារចុះបញ្ជីម៉ាក និងកិច្ចការដទៃទៀត ដែលទាក់ទងនឹងម៉ាក និងម៉ាកសម្គាល់ភូមសាស្ត្រទំនិញ ឲ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់ភាពងាយស្រួល ដល់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្ម និងការការពារសិទ្ធិរបស់ខ្លួន តាមរយៈតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីក្លាយជា ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជាជំនាន់ទី ១ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ចំនួន ៦៤ ម៉ោង ដែលមានបេក្ខជន បានប្រឡងជាប់ជាស្ថាពរចំនួន ៣៤ នាក់ ហើយបានក្លាយខ្លួនភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា។ វគ្គបណ្តុះបណ្តាលជំនាន់ទី២ នេះ មានសិក្ខាកាម ចំនួន ៥៩ នាក់ ដែលរួមមានសមាសភាពមន្ត្រីមកក្រសួង-ស្ថាប័ននានាចំនួន ២៤ នាក់ និងវិស័យឯកជនចំនួន ៣៤ នាក់។

ឆ្លៀតឱកាសនេះខ្ញុំសូមរំលឹក ដល់សិក្ខាកាមទាំងអស់ ត្រូវខិតខំរៀនសូត្រនូវជំនាញបច្ចេកទេសកម្មសិទ្ធិបញ្ញា ចែករំលែកនូវបទពិសោធន៍របស់ខ្លួន ធ្វើយ៉ាងណាឲ្យ វគ្គបណ្តុះបណ្តាលនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងប្រកាសបើកកម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាពដើម្បីក្លាយជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា។

សូមអរគុណ